ឆ្នាំទី១៦ លេខ ៦៥ សប្តាហ៍ទី ១ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៦ រាជកិច្ច ទំព័រ ៧៦៤២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....៩៥....សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកំណត់និមិត្តសញ្ញានិងត្រា
## របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៤ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ១៨៦ អនក្រ.តត ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល/

## សម្រេច

**ប្រការ១ .-**

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនមាននិមិត្តសញ្ញានិងត្រារបស់ខ្លួន ស្របតាមមាត្រា១០នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២ .-**

និមិត្តសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនមានសញ្ញានិងអត្ថន័យដូចខាងក្រោម៖

**ក- សញ្ញា**

- រូបព្រះភក្ត្របដិមាអវលោកិតេស្វរៈប្រាសាទបាយ័នញញឹមនៅក្នុងរង្វង់មូលខៀវចាស់ចន្លោះខ្សែព័ទ្ធពីរជាន់
- អក្សរឆ្លាក់ឈ្មោះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនជាភាសាខ្មែរនៅខាងលើ និងភាសាអង់គ្លេសនៅខាងក្រោមហើយខណ្ឌដោយក្បាច់ចម្លាក់ផ្កាចន្ទន៍ចំនួនពីរនៅសងខាងក្នុងចន្លោះរង្វង់មូលខៀវចាស់នៃខ្សែព័ទ្ធពីរជាន់
- រង្វង់នៃនិមិត្តសញ្ញាទ្រអមដោយកម្រងស្លឹករំដួលពណ៌បៃតងខ្ចីនៅខាងក្រោម
- អក្សរកាត់ឈ្មោះជាភាសាខ្មែរនិងអង់គ្លេសឆ្លាក់អមសងខាងផ្កាចន្ទន៍នៅលើកម្រងស្លឹករំដួល។

**ខ- អត្ថន័យ**

- **ព្រះភក្ត្រអវលោកិតេស្វរៈប្រាសាទបាយ័ន** ព្រះភក្ត្រមួយចំនួនក្នុងចំណោមព្រះភក្ត្រ២១៦នៃកំពូលប្រាសាទបាយ័នដែលបែរមុខទៅទិសខាងត្បូង មានភាពញញឹមស្ងប់ស្ងាត់បង្ហាញពីទឹកចិត្តព្រហ្មវិហារធម៌ សណ្តោសប្រណី យកចិត្តទុកដាក់ចំពោះសុខទុក្ខប្រជាជន។

- **រង្វង់មូល** និរន្តរភាពជាអមតៈ ជានិមិត្តរូបព្រះអាទិត្យ ព្រះចន្ទ ចក្រវាឡ តំណាងឱ្យការឯកភាព ការការពារបូរណភាព សុចរិតភាព និងភាពសុខដុម។

- **ពណ៌ខៀវ** តំណាងឱ្យភាពស្មោះត្រង់ ការទទួលខុសត្រូវ ភាពស្ងប់ស្ងាត់ សន្តិភាព មិត្តភាព សង្គ្រោះមនុស្សជាតិ និងការរីតចំណងទំនាក់ទំនង ទាំងបរិមាណនិងគុណភាពជារៀងរហូត។

- **កម្រងស្លឹកនិងផ្ការំដួល** ជារុក្ខជាតិត្រូវបានជ្រើសរើសតំណាងឱ្យផ្កាជាតិកម្ពុជា ជាដើមរុក្ខជាតិដែលខ្មែរគ្រប់រូបស្គាល់និងស្រឡាញ់ចូលចិត្ត ដោយមានក្លិនក្រអូបសាយ ហើយផ្លែទុំគេអាចបរិភោគបាន។

- **រូបផែនទីពិភពលោក** គឺសមាហរណកម្មសកម្មភាពយុវជនកម្ពុជា ទៅក្នុងតំបន់និងពិភពលោក។

**ប្រការ៣ .-**

ត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនមានទម្រង់និងខ្លឹមសារដូចខាងក្រោម៖

**ក- ទម្រង់**

- មានរាងរង្វង់មូល
- មានខ្សែព័ទ្ធខាងក្រៅចំនួនពីរជាន់និងខាងក្នុងចំនួនមួយជាន់
- នៅចំកណ្តាលមានរូបប្រាសាទអង្គរវត្តកំពូលបី។

**ខ- ខ្លឹមសារ**

- ខាងលើដាក់ថា"ព្រះរាជាណាចក្រកម្ពុជា"
- ខាងក្រោមដាក់ថា"ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន"។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ៩៤ សសរ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៦
## ស្តីពីការកំណត់និមិត្តសញ្ញានិងត្រា
## របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

### គំរូនិមិត្តសញ្ញារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

### គំរូត្រារបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន